00281292

**Declassified to Public**
**06 September 2012**

E2/89.9

**ជូនចំពោះ កញ្ញា ម៉ុច សុវណ្ណារី**

ប្រាកដណាស់ នាងខ្ញុំបានស្នើសុំវិធានសំរាប់ការពារ ។

នាងខ្ញុំធ្វើការនៅក្រុមហ៊ុនអាកាសចរខាងផ្នែក Secteur Asie តាំងពីប៉ុន្មានឆ្នាំមកហើយ ។ អាស្រ័យហេតុនេះហើយ នាងខ្ញុំធ្វើដំណើរជាញឹកញាប់ទៅ ប៉េកាំង និងសៀងហៃ ។

សុវត្ថិភាព និងសន្តិសុខ គឺជាមានសារៈសំខាន់ណាស់សំរាប់អាជីពរបស់ខ្ញុំ ។

នៅខែ ឧសភា ២០០៣ នៅពេលដែលនាងខ្ញុំមកដល់ប៉េកាំងអស់រយៈពេល៥ម៉ោង ពេលនោះមានមនុស្សម្នាក់ឈ្មោះលោក Kek Erang ដែលគាត់ប្រាប់ខ្ញុំថាធ្វើការជាអគ្គរាជទូតកម្ពុជាប្រចាំនៅប៉េកាំងនោះ បានទាក់ទងមកខ្ញុំទៅដល់បន្ទប់របស់ខ្ញុំនៅឯសណ្ឋាគារ នៅពេលដែលខ្ញុំទទួល នូវជើងហោះហើររយៈពេលវែង ។

ស្ថិតនៅក្នុងបញ្ជីឈ្មោះបុគ្គលិកក្នុងជើងហោះហើរ គ្មាននរណាអាចដឹងពីលេខបន្ទប់សណ្ឋាគាររបស់យើងទេបើយើង មិនផ្តល់អោយគេនោះ។ វាគ្រាន់តែជាវិធានការការពារដែលជាប់ពាក់ព័ន្ធនឹងការងាររបស់ខ្ញុំតែប៉ុណ្ណោះ ។

បុគ្គលរូបនេះដែលខ្ញុំមិនស្គាល់ និងមិនដែលបានឃើញសោះនោះ បាននិយាយមកខ្ញុំដំបូងជាភាសាខ្មែរដោយលក្ខណៈគំរោះគំរើយ បន្ទាប់មកជាភាសាអង់គ្លេស ហើយប្រហែលជាចង់ដឹងពីចំណេះដឹងផ្នែកភាសារបស់ខ្ញុំ ។

មុននឹងបញ្ចប់ជីវិតនៅមន្ទីរ ស ២១ ឪពុករបស់ខ្ញុំ អ៊ុក កេត បានឆ្លងកាត់ទីក្រុងប៉េកាំង ។ មានភាពច្របូកច្របល់នៃសេចក្តីសម្រេចជាច្រើនទាក់ទងនឹង ចិន-ខ្មែរ ។

ពីរបីខែមុន នាងខ្ញុំបានទុកលិខិតសរសេរដោយដៃមួយជូនចំពោះលោក ចាន់ យូរ៉ាន់ ដែលនៅតែចង់ដឹងពីប្រវត្តិរបស់នាងខ្ញុំ ពីអាសយដ្ឋានតែមួយគត់ដែលអាចទាក់ទងបានគឺនៅសណ្ឋាគារចិនមួយដោយដាក់ថា "COMPOUND" សំរាប់កម្ពុជា ។ លោក Kek Erang បានអានអោយខ្ញុំស្តាប់មួយពាក្យម្តងៗ ។

នាងខ្ញុំកាត់យល់ថាលោក ចាន់ យូរ៉ាន់ ដោយសារតែកន្លែងរបស់គាត់មានការពិបាកចូលជួបសម្រាប់យើង (ខ្ញុំ និងម្តាយរបស់ខ្ញុំ) និយាយម្យ៉ាងទៀតថាវាគឺជារឿងមិនពិត មិនដែលបានទទួលបានលិខិតរបស់ខ្ញុំទាល់តែសោះ ។ ម្យ៉ាងទៀត វាគ្រាន់តែជាគំនាបដែលរង់ចាំចម្លើយពីនរណាម្នាក់តែប៉ុណ្ណោះ ប៉ុន្តែលើសពីនេះទៅទៀត លិខិតបែរជាស្ថិតនៅក្នុងដៃបុគ្គលដែលបានអាននោះទៅវិញ ។

បន្ទាប់ពីបានសន្ទនាគ្នារួចមក ភ្លាមៗនោះនាងខ្ញុំត្រូវបានទទួលដោយលោក EMMANUEL LEMOINE ដែលជាជនជាតិបារាំងទទួលខុសត្រូវនៅសណ្ឋាគារដែលយើងស្នាក់នៅនោះ ។ គាត់បានស្វែងរកអ្នកដែលបានផ្តល់ដំណឹងពីការមកដល់របស់ខ្ញុំ ។ ហើយដូចគ្នាដែរ គាត់បានស្នើសុំខ្ញុំអោយមានការការពារនៅជាន់ដែលខ្ញុំស្នាក់នៅ ។ ការការពារ ដែលនាងខ្ញុំបានបដិសេធដោយភាពច្របូកច្របល់ក្នុងចិត្ត ។

លោក Lemoine មិនអាចអោយមកខ្ញុំនូវឯកសារជាលាយលក្ខណ៍អក្សរប្រាប់ពីអ្វីដែលខ្ញុំបានទទួលនោះទេ តាមរយៈការនិយាយទូរស័ព្ទ ។ ផ្ទុយទៅវិញ គាត់ចង់ដឹងថានរណាដែលទទួលបន្ទុកក្នុងការរៀបចំទុកមុនសំរាប់ការមកដល់របស់ខ្ញុំ ហើយអ្នកនោះគឺ ជាគយព្រលានយន្តហោះ ។

នាងខ្ញុំសូមបញ្ជាក់ថា គឺលោក Kek Erang ដែលបានអោយខ្ញុំនូវលេខទូរស័ព្ទរបស់គាត់ ។ នាងខ្ញុំបានទូរស័ព្ទទៅលេខនោះព្រោះខ្ញុំទាល់គំនិត ។ យើងមិនបាននិយាយគ្នាអោយបានច្រើននោះទេ ព្រោះគាត់មិនបានឆ្លើយតបរាល់សំនួររបស់ខ្ញុំទេ ។ ផ្ទុយទៅវិញ គាត់នៅស្ងៀមស្ងាត់ ។ គាត់បែរជាចង់ដឹងថានៅពេលណាខ្ញុំត្រឡប់មកវិញ ហើយគាត់បបួលខ្ញុំផឹកតែជាមួយគ្នាលើកក្រោយទៀត ។

នេះគឺជាពាក្យដែលពួកខ្មែរក្រហមប្រើ ។ តាមរបាយការណ៍របស់កាសែត Nouvel Observateur របស់លោក Bizot បានបកស្រាយថាជា" ការកម្ទេចមនុស្ស " ។

បច្ចុប្បន្ន នាងខ្ញុំធ្វើការជាធម្មតានៅទីភ្នាក់ងារអាស៊ី ។

នាងខ្ញុំទុកចិត្តលើវិជ្ជាជីវៈរបស់អ្នកក្នុងការអនុវត្តនូវវិធានការការពារសំរាប់សាក្សីដើមបណ្តឹងរដ្ឋប្បវេណីដែលនៅមានជីវិតនៅឡើយ ។

សូមអ្នកស្រីទទួលនូវការគោរពរាប់អានអំពីនាងខ្ញុំ ។

**កញ្ញា អ៊ុក នារី**